ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៨-០៥-១៥៧ ប្រ.ក

# ប្រ ក ា ស

## ស្តីពី

## ការកំណត់លេខអត្តសញ្ញាណធនាគារ

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម ១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង ឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម ១០០៥/០៣០ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់
- យោងតាមសំណើរបស់អគ្គនាយកដ្ឋាននៃធនាគារជាតិនៃកម្ពុជា
- តាមស្មារតីអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា នាថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៨

## ស ម្រ េ ច

**ប្រការ ១.-**

កំណត់លេខអត្តសញ្ញាណសម្រាប់សម្គាល់គ្រឹះស្ថានធនាគារ ដើម្បីចារឹកលេខកូដធនាគារនៅលើមូលប្បទានប័ត្រ ដែលអាចអានបានដោយម៉ាស៊ីន ស្របតាមមូលប្បទានប័ត្រស្តង់ដារ ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

គ្រប់មូលប្បទានប័ត្រទាំងអស់ ត្រូវតែចារឹកនូវលេខអត្តសញ្ញាណសម្រាប់សម្គាល់ដូចតទៅ ÷

ក- លេខកូដធនាគារដែលបោះផ្សាយមូលប្បទានប័ត្រ

ខ- លេខកូដសាខារបស់ធនាគារដែលចេញផ្សាយមូលប្បទានប័ត្រ និង

គ- លេខកូដផ្ទៀងផ្ទាត់ (Check digit) ។




**ប្រការ ២.-**

លេខកូដសម្រាប់សម្គាល់ធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានធនាគារ ត្រូវបានកំណត់ដូចតទៅ ÷

| ឈ្មោះគ្រឹះស្ថានធនាគារ | លេខកូដ |
|---|---|
| ធនាគារជាតិនៃកម្ពុជា | ១០០ |
| ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា | ០០១ |
| ធនាគារកម្ពុជាពាណិជ្ជចំកាត់ | ០០៣ |
| ធនាគារកម្ពុជាសាធារណៈ ចំកាត់ | ០០៤ |
| ធនាគារកាណាឌីយ៉ា ក្រុមហ៊ុនអនាមិក | ០០៥ |
| ធនាគារក្រុងថៃ មហាជន សាខាភ្នំពេញ | ០០៩ |
| ធនាគារកម្ពុជាអាស៊ីចំកាត់ | ០១៦ |
| សាជីវកម្មធនាគារសឹង្ហបូរី ចំកាត់ | ០១៨ |
| ធនាគារមេយប៊ែង សាខាភ្នំពេញ | ០២០ |
| ធនាគារសហពាណិជ្ជ ក្រុមហ៊ុនអនាមិក | ០២៦ |
| ធនាគារ មេគង្គកម្ពុជា មហាជនទទួលខុសត្រូវមានកម្រិត | ០៣២ |
| ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ | ០៣៦ |
| ធនាគារអភិវឌ្ឍជនបទ | ០៣៨ |
| ធនាគារពាណិជ្ជទី១ សាខាភ្នំពេញ | ០៤០ |
| ធនាគារអេស៊ីលីដា ភីអិលស៊ី | ០៤១ |
| ធនាគារឯកទេស ប៉េង ហេង អេស អឹម អ៊ី | ០៤២ |
| ធនាគារវឌ្ឍនៈ | ០៤៣ |
| ធនាគារ អេ អ៊ិន ហ្ស៊ិត រ៉ូយ៉ាល់កម្ពុជា | ០៤៤ |

| | |
|---|---|
| ធនាគារឯកទេស វិនិយោគទី១ | ០៤៧ |
| ធនាគារ ខេមខូលិមីធីត | ០៥២ |
| ធនាគារ ស៊ិនហានខ្មែរ | ០៥៣ |
| ធនាគារ វី. អាយ . ភី | ០៥៤ |
| ធនាគារ វិនិយោគរុងរឿង | ០៥៥ |
| ធនាគារជប៉ុន ម៉ារូហាន់ | ០៥៦ |
| ធនាគារ ប៊ូយ៉ុង ខ្មែរ | ០៦១ |
| ធនាគារ ភ្នំពេញពាណិជ្ជ | ០៥៨ |
| ធនាគារ អូ. អេស. ខេ អិនដូឆាយណាលីមីធីត | ០៥៧ |
| ធនាគារ ខ្មែរយូញៀន | ០៥៩ |
| ធនាគារឯកទេស បើស | ០៦០ |
| ធនាគារ អង្គរកាពីតាល់ | ០៦៣ |

**ប្រការ ៣.~**

ក- លេខកូដសម្រាប់សម្គាល់ទីស្នាក់ការកណ្តាល និងសាខាធនាគារជាតិនៃកម្ពុជានៅតាមបណ្តាខេត្ត-ក្រុង ត្រូវបានកំណត់ដូចខាងក្រោម ÷

| ឈ្មោះធនាគារ | លេខកូដ |
|---|---|
| ធនាគារជាតិនៃកម្ពុជា | ០០១ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តកណ្តាល | ០០២ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តកំពង់ចាម | ០០៣ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តបាត់ដំបង | ០០៤ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តព្រៃវែង | ០០៥ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តសៀមរាប | ០០៦ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តកំពង់ធំ | ០០៧ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តតាកែវ | ០០៨ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តស្វាយរៀង | ០០៩ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តពោធិ៍សាត់ | ០១០ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តកំពង់ឆ្នាំង | ០១១ |

| | |
|---|---|
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តកំពង់ស្ពឺ | ០១២ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តកំពត | ០១៣ |
| សាខា ធនាគារជាតិនៃកម្ពុជា ក្រុងព្រះសីហនុ | ០១៤ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តកោះកុង | ០១៥ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តព្រះវិហារ | ០១៦ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តក្រចេះ | ០១៧ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តរតនគិរី | ០១៨ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តមណ្ឌលគិរី | ០១៩ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តស្ទឹងត្រែង | ០២០ |
| សាខា ធនាគារជាតិនៃកម្ពុជា ខេត្តបន្ទាយមានជ័យ | ០២១ |
| សាខា ធនាគារជាតិនៃកម្ពុជា ក្រុងភ្នំពេញ | ០២៣ |

ខ- ចំពោះលេខកូដសម្គាល់សាខាគ្រឹះស្ថានធនាគារ នឹងត្រូវបានកំណត់ដោយសាមីគ្រឹះស្ថាននីមួយៗ ហើយសាមីគ្រឹះស្ថានត្រូវផ្ញើបញ្ជីលេខកូដសម្គាល់សាខារបស់ខ្លួនដែលបានកំណត់ហើយនោះ មកធនាគារជាតិនៃកម្ពុជា ។

## ប្រការ ៤.-

ចំពោះលេខកូដសម្រាប់សម្គាល់គ្រឹះស្ថានធនាគារ និង សម្គាល់សាខាធនាគារជាតិនៃកម្ពុជា ដែលត្រូវបង្កើតថ្មី នឹងត្រូវបានកំណត់ដោយសេចក្តីជូនដំណឹងរបស់ធនាគារជាតិនៃកម្ពុជា ។

## ប្រការ ៥.-

លេខកូដផ្ទៀងផ្ទាត់ (Check digit) ត្រូវបានប្រើសម្រាប់ផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវនៃលេខកូដអត្តសញ្ញាណធនាគារដែលចែងក្នុងប្រការ១ ។ វិធីសាស្ត្រដាក់លេខកូដផ្ទៀងផ្ទាត់នេះ នឹងត្រូវបានកំណត់ដោយធនាគារជាតិនៃកម្ពុជា ។

## ប្រការ ៦.-

ក្នុងករណីមានការផ្លាស់ប្តូរទីតាំងសាខាគ្រឹះស្ថានធនាគារ ឬបង្កើតសាខាគ្រឹះស្ថានធនាគារបន្ថែមទៀត សាមីគ្រឹះស្ថានធនាគារត្រូវផ្តល់ដំណឹងជាមុនមកធនាគារជាតិនៃកម្ពុជាក្នុងរយៈពេល ១០ ថ្ងៃនៃថ្ងៃធ្វើការ ។

ក្នុងករណីដែលសាខាគ្រឹះស្ថានធនាគារណាមួយបិទទ្វារបញ្ឈប់សកម្មភាពអាជីវកម្ម លេខកូដសាខាគ្រឹះស្ថានធនាគារនោះ មិនអនុញ្ញាតអោយយកទៅប្រើសម្រាប់សម្គាល់សាខាគ្រឹះស្ថានធនាគារដែលបើកថ្មីឡើយ ។ សាខាគ្រឹះស្ថានធនាគារថ្មីត្រូវកំណត់លេខកូដថ្មី ។

**ប្រការ ៧.-**

ការប្រើប្រាស់លេខអត្តសញ្ញាណសម្រាប់សម្គាល់គ្រឹះស្ថានធនាគារដូចមានចែងខាងលើ នឹងចាប់ផ្តើមអនុវត្តនៅពេលដែលមូលប្បទានប័ត្រស្តង់ដារត្រូវបានដាក់ឱ្យប្រើប្រាស់ ។

**ប្រការ ៨.-**

លិខិតបទដ្ឋានទាំងឡាយណាដែលពាក់ព័ន្ធនឹងការដាក់លេខអត្តសញ្ញាណធនាគារ ត្រូវចាត់ទុកជានិរាករណ៍ចាប់ពីថ្ងៃដែលមូលប្បទានប័ត្រស្តង់ដារត្រូវបានដាក់ឱ្យប្រើប្រាស់ ។

**ប្រការ ៩.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារ នៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឹងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀង១ខ្លួន ។

**ប្រការ ១០.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។៚

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ២០០៨

**ទេសាភិបាល**

**ជា_ចាន់តូ**

**កន្លែងទទួល**

- ដូចប្រការ ៩
  " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាបជាព័ត៌មាន "
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីចុះផ្សាយក្នុងរាជកិច្ច "